ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៣៤៥ អយក.ជាវ

ថ្ងៃ ច័ន្ទ ៥ កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៥

## ជម្រាបជូន

- **ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទក្រសួង**
- **លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**
- **លោក លោកស្រី ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រី នាយក នាយិកាសាលារៀនសាធារណៈគ្រប់កម្រិត**

**កម្មវត្ថុ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីទូរសព្ទដៃវៃឆ្លាត (EFMS App) នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា លើមុខងារការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងព័ត៌មានអប់រំ និងការគ្រប់គ្រងធនធានមនុស្ស។

**យោង ៖** ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ របស់នាយកដ្ឋានហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ ក្រសួងបានអភិវឌ្ឍកម្មវិធីទូរសព្ទដៃវៃឆ្លាត (EFMS App) ដែលបានធ្វើសន្ទានកម្មរវាងប្រព័ន្ធព័ត៌មានវិទ្យាទាំងបីប្រកបដោយជោគជ័យ គឺប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS) និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HRMIS) ដោយបង្កើតបានជាថ្នាលទិន្នន័យរួម ក្នុងគោលបំណងសម្រួលប្រតិបត្តិការ បង្កើនសង្គតិភាពទិន្នន័យ សុវត្ថិភាពខ្ពស់ ទិន្នន័យទាន់ពេលវេលា និងមានប្រសិទ្ធភាព ដែលអាចប្រើប្រាស់បាននៅលើប្រព័ន្ធប្រតិបត្តិការ iOS និង Android។ កម្មវិធីនេះអាចជួយសម្រួលដល់ថ្នាក់ដឹកនាំក្រសួង អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនសាធារណៈទូទាំងប្រទេស ដើម្បីទាញយកទិន្នន័យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងព័ត៌មានអប់រំ និងការគ្រប់គ្រងធនធានមនុស្សរបស់អង្គភាពសាមី បានយ៉ាងរហ័សប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីទូរសព្ទដៃវៃឆ្លាត (EFMS App) នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងអប់រំ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

យុវជន និងកីឡា លើមុខងារការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងព័ត៌មានអប់រំ និងការគ្រប់គ្រងធនធានមនុស្ស សម្រាប់ប្រើប្រាស់ជាផ្លូវការចាប់ពីឆ្នាំ២០២៥ តទៅ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាប និង ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ